
Kids of Destiny
Reaching the Forgotten
www.kidsofdestiny.org

## 2.02 **បងប្រុសរបស់យ៉ូសែបនៅស្រុកអេស៊ីព្ទ**

លោកយ៉ូសែបត្រូវបានតែងតាំងជាអភិបាល លើស្រុកអេស៊ីព្ទទាំងមូល។ គាត់ទទួលបន្ទុករាល់អាហារ ដែលត្រូវបានដាំដុះក្នុងអំឡុងពេលប្រាំពីរឆ្នាំដំបូងនោះ។ ដោយសារគាត់គ្រប់គ្រងដំណាំបានល្អ និងមានស្បៀងអាហារជាច្រើនត្រូវបានទុកសម្រាប់ពេលដែលគ្មានដំណាំដុះឡើង។ ប្រជាជនមកពីប្រទេសផ្សេងៗគ្នា បានមកស្នើសុំអាហារនោះ។ យ៉ូសែបអាចជួយពួកគេបាន ដោយសារគាត់បានជឿទុកចិត្តលើព្រះអម្ចាស់ ហើយបានរៀបចំផែនការយ៉ាងល្អសម្រាប់ពេលនេះ ។

នៅពេលលោកយ៉ាកុបដែលជាឪពុករបស់យ៉ូសែបបានឮថា មានស្បៀងអាហារនៅស្រុកអេស៊ីព្ទ ដូច្នេះលោកក៏បានប្រាប់កូនប្រុសរបស់លោកឲ្យចាកចេញពីផ្ទះដែលនៅស្រុកកាណាន ហើយទៅទិញស្បៀងអាហារនៅស្រុកអេស៊ីព្ទ។ បងប្អូន១០នាក់បានទៅស្រុកអេស៊ីព្ទ។ ប្អូនពៅឈ្មោះបេនយ៉ាមីនបាននៅពីក្រោយគេ។ ពេលពួកគេទៅដល់ ហើយសុំទិញម្ហូប យ៉ូសែបបានឃើញហើយក៏ដឹងថា ទាំងនោះជាបងប្អូនរបស់គាត់។ ប៉ុន្តែបងប្អូនរបស់យ៉ូសែបមិនបានដឹងថា បុរសនេះគឺជាយ៉ូសែបជាប្អូនរបស់ពួកគេទេ។ បន្ទាប់មកយ៉ូសែបបានសួរសំណួរជាច្រើនទៅពួកគេ។ ពួកគេបានសារភាពចំពោះគាត់ថា ពួកគេមានប្អូនប្រុសពៅម្នាក់ ហើយពួកគេក៏មានប្អូនប្រុសម្នាក់ទៀតដែរ ប៉ុន្តែគាត់មិននៅជាមួយពួកគេទៀតទេ។ (ប្អូនប្រុសនោះគឺជាយ៉ូសែប)។ លោកយ៉ូសែបបាននិយាយថា "សូមបង្ហាញខ្ញុំ ថាអ្នកជាមនុស្សស្មោះត្រង់។ ត្រឡប់ទៅផ្ទះវិញ ហើយនាំប្អូនប្រុសរបស់អ្នកមកវិញ។ បងៗគាត់ក៏បានត្រឡប់ទៅផ្ទះ និងឪពុករបស់ពួកគេឈ្មោះយ៉ាកុបវិញ ។ ពួកគេបានប្រាប់ឪពុកពួកគេថា គេត្រូវបានស្នើសុំឲ្យនាំបេនយ៉ាមីនត្រឡប់ទៅស្រុកអេស៊ីព្ទវិញ ។ លោកយ៉ាកុបតូចចិត្តណាស់ ។ គាត់ខ្លាចថា គាត់នឹងបាត់បង់បេនយ៉ាមីនដូចដែលគាត់បានបាត់បង់យ៉ូសែបដែរ ។ ទោះជាយ៉ាងណាក៏ដោយ គាត់ត្រូវតែអនុញ្ញាតឲ្យបេនយ៉ាមីនទៅ ព្រោះគ្រួសារគាត់ទាំងមូលប្រាកដជាស្លាប់ដោយអត់អាហារ ។

នៅពេលដែលបងប្អូនទាំងអស់ទៅដល់ស្រុកអេស៊ីព្ទ ហើយបានទៅជួបលោកយ៉ូសែប ពេលនោះពួកគេមានការភ្ញាក់ផ្អើលនិងភ័យខ្លាចណាស់ ។ យ៉ូសែបបានស្នើសុំ ឲ្យពួកគេទៅផ្ទះរបស់គាត់ ។ ពួកគេមានអារម្មណ៍ភ័យខ្លាច ព្រោះពួកគេបានធ្វើបាបយ៉ូសែប ។ ពួកគេគ្មានជម្រើសក្រៅពីទៅ ។ លោកយ៉ូសែបបានរៀបចំពិធីជប់លៀងដ៏ធំមួយសម្រាប់ពួកគេ ។ គាត់បានប្រាប់ពួកគេថា កុំបារម្ភឡើយ ។ យ៉ូសែបបាននិយាយថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត! ពួកគេបានក្រាបថ្វាយបង្គំលោកយ៉ូសែប ហើយឲ្យកាដូរដែលឪពុករបស់ពួកគេ ដែលជាយ៉ាកុបផ្ញើរមកឲ្យ ។ លោកយ៉ូសែបបានចាប់ផ្តើមសួរសំណួរម្តងទៀត ។ លោកយ៉ូសែបបានសួរថា៖ «តើឪពុកអ្នកយ៉ាងម៉េច? "ហើយតើនេះជាប្អូនប្រុសដែលអ្នកបាននិយាយនោះឬ?" បន្ទាប់មកគាត់បានទៅបន្ទប់មួយ ហើយយំ ដោយសារតែបានឃើញបងប្អូនរបស់គាត់ ។ បន្ទាប់ពីនោះមកគាត់បានបង្កើតផែនការមួយ ។ គាត់បានសុំ ឲ្យអ្នកបម្រើរបស់គាត់ដាក់ពែងប្រាក់មួយទៅក្នុងកាបូបស្ពាយរបស់បេនយ៉ាមីនដោយសម្ងាត់ ។ ក្រោយមកគាត់នឹងចោទប្រកាន់បងប្អូនគាត់ថា បានលួចបន្ទាប់ពីពួកគេបានចាកចេញ ហើយវិលត្រឡប់ទៅផ្ទះវិញ ។ តើអ្នកណាបានលួចយកពែងរបស់ខ្ញុំ? លោកយ៉ូសែបបានសម្លុតសួរ ។ អ្នកណាដែលបានលួចយកវា គឺនឹងនៅត្រូវជាប់នឹងស្រុកអេស៊ីព្ទជាបាវបម្រើរបស់យើង ។

បងៗភ័យខ្លាចជាខ្លាំង នៅពេលដែលរកឃើញពែងនោះនៅជាមួយបេនយ៉ាមីន ។ បងប្រុសគាត់ម្នាក់ឈ្មោះយូដា បានពោលថា៖ «សូមកុំទុកបេនយ៉ាមីនជាបាវបម្រើរបស់លោកឡើយ។ សូមយកខ្ញុំប្របាទជំនួសវិញចុះ។ ឪពុករបស់យើងចាស់ណាស់ហើយ លោកច្បាស់ជាស្លាប់ ប្រសិនបើបេនយ៉ាមីនមិនត្រឡប់ទៅជួបគាត់វិញ។ យ៉ូសែបមិនអាចលាក់បាំងថា គាត់ជានរណាពីពួកគេយូរទៀតបានទេ ។ គាត់ក៏បានប្រាប់ពួកគេថា គាត់គឺជាប្អូនប្រុសរបស់ពួកគេទេ គឺយ៉ូសែប ។ គាត់បាននិយាយថា "កុំភ័យខ្លាចឡើយ ព្រោះអ្នកបានលក់ខ្ញុំឱ្យឈ្មួញអេហ្ស៊ីបតាំងពីយូរយារណាស់មកហើយ។ ព្រះអម្ចាស់ទ្រង់មានផែនការឲ្យខ្ញុំមកនៅទីនេះ ហើយអាចជួយសង្គ្រោះអ្នកទាំងអស់គ្នាក្នុងពេលទុរ្ភិក្សនេះបាន ។ ចូរត្រលប់ទៅផ្ទះវិញ ហើយនាំឪពុក និងក្រុមគ្រួសាររបស់យើងទាំងមូលមក ។ នាំយកសត្វរបស់អ្នកទាំងអស់ផងដែរ ។ ខ្ញុំនឹងរកកន្លែងពិសេសសម្រាប់អ្នកដើម្បីរស់នៅពេញមួយជីវិតរបស់អ្នក ។ បន្ទាប់មកយ៉ូសែបបានឲ្យអំណោយជាច្រើនដល់ពួកគេ ។
ពួកគេបានត្រឡប់ទៅស្រុកកាណានវិញ ហើយបានប្រាប់ឪពុករបស់ពួកគេថា យ៉ូសែបនៅរស់ហើយបានក្លាយជាអ្នកគ្រប់គ្រងលើស្រុកអេស៊ីព្ទថែមទៀតផង ។ ក្នុងចិត្តរបស់លោកយ៉ាកុបពិតជារីករាយណាស់ ។ លោកយ៉ាកុបមានប្រសាសន៍ថា៖ «ល្អមហើយដែលកូនប្រុសខ្ញុំមានជីវិតរស់ ហើយខ្ញុំនឹងជួបគេម្តងទៀតមុនខ្ញុំស្លាប់» ។

**(លោកុប្បត្តិ ជំពូក ៤២-៤៥)**

## 2.02 បងប្រុសរបស់យ៉ូសែបនៅស្រុកអេស៊ីព្ទ សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

**កំណត់សម្គាល់**:

១) លោកយ៉ូសែបបានគ្រប់គ្រងលើស្រុកអេស៊ីព្ទ ។ អស់រយៈពេលប្រាំពីរឆ្នាំខណៈពេលដែលស្បៀងអាហារកំពុងកើនឡើង លោកយ៉ូសែបបានសន្សំស្បៀងអាហារគ្រប់គ្រាន់ សម្រាប់ឆ្នាំដែលដំណាំមិនលូតលាស់ ។ ប្រជាជនមកពីគ្រប់ទិសទីបានសុំយ៉ូសែបចែកស្បៀងអាហារ ។

២) ឪពុករបស់លោកយ៉ូសែប គឺលោកយ៉ាកុប និងបងប្អូនរបស់លោករស់នៅក្នុងស្រុកកាណាន ។ ពួកគេត្រូវការអាហារផងដែរ ។ យ៉ាកុបបានបញ្ជូនបងប្អូន ១០នាក់នោះ ដើម្បីទៅស្រុកអេស៊ីព្ទ ដើម្បីរកស្បៀងអាហារ ។

៣) យ៉ូសែបបានប្រាប់ពួកបងៗគាត់ឲ្យបង្ហាញថា ពួកគេពិតជាមនុស្សស្មោះត្រង់ ដែលនឹងនាំប្អូនប្រុសរបស់គេ បេនយ៉ាមីនទៅស្រុកអេស៊ីព្ទវិញ ។ លោកយ៉ូសែបបានដឹងថា ទាំងនេះគឺជាបងៗរបស់គាត់ ។ តែពួកគេមិនដឹងថា គាត់ជាប្អូនប្រុសរបស់ពួកគេឈ្មោះយ៉ូសែបទេ ។

៤) នៅពេលដែលបេនយ៉ាមីនត្រូវបាននាំទៅស្រុកអេស៊ីព្ទវិញហើយ យ៉ូសែបបានលាក់ពែងប្រាក់មួយនៅក្នុងសាកាដូរបស់បេនយ៉ាមីន ដូច្នេះគាត់អាចចោទប្រកាន់បេនយ៉ាមីនថា បានលួចរបស់គាត់ ។ លោកយ៉ូសែបនឹងចាប់បេនយ៉ាមីនទុកជាបាវបម្រើ ។

៥) លោកយូដាដែលជាបងប្រុសម្នាក់បាននិយាយថាគាត់នឹងធ្វើជាបាវបម្រើសម្រាប់យ៉ូសែបជំនួសបេនយ៉ាមីនវិញ។

៦) លោកយ៉ូសែបបានប្រាប់ពួកគេថា គាត់គឺជាបងប្អូនរបស់ពួកគេ ។ គាត់បានប្រាប់ពួកគេឲ្យត្រឡប់ទៅផ្ទះវិញ ហើយនាំឪពុក និងសមាជិកគ្រួសារទាំងអស់ត្រឡប់ទៅស្រុកអេស៊ីព្ទវិញ រួមជាមួយសត្វទាំងអស់ផង ។ គាត់នឹងរកកន្លែងសម្រាប់ពួកគេរស់នៅ ។

**សំណួរ**:

1) តើលោកយ៉ូសែបមានមុខងារអ្វីជាអ្នកគ្រប់គ្រងលើស្រុកអេស៊ីព្ទ?
2) តើលោកយ៉ាកុបបានធ្វើអ្វីនៅពេលគ្រួសាររបស់គាត់ត្រូវការអាហារ?
3) តើលោកយ៉ូសែបបានសុំឲ្យបងៗគាត់នាំអ្នកណាត្រឡប់ទៅស្រុកអេស៊ីព្ទវិញ?
4) តើលោកយ៉ូសែបបានធ្វើអ្វី ដើម្បីចោទប្រកាន់បេនយ៉ាមីនថាបានលួចរបស់គាត់?
5) តើអ្នកណានិយាយថា គាត់នឹងធ្វើជាទាសករជំនួសបេនយ៉ាមីនវិញ?
6) តើយ៉ូសែបបានប្រាប់បងប្អូនរបស់គាត់ឲ្យធ្វើអ្វី បន្ទាប់ពីគាត់បានប្រាប់ពួកគេថាគាត់ជានរណា?

**ចម្លើយ**:

1) ការងាររបស់លោកយ៉ូសែប គឺដើម្បីសន្សំស្បៀងអាហារក្នុងកំឡុងពេលប៉ុន្មានឆ្នាំ ដែលវាលូតលាស់ល្អ ដើម្បីប្រាកដថាមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ឆ្នាំដែលគ្មានអាហារ ។
2) លោកយ៉ាកុបបានបញ្ជូនបងប្អូន ១០នាក់របស់យ៉ូសែបឲ្យទៅស្រុកអេស៊ីព្ទ ដើម្បីទិញម្ហូបអាហារ ។
3) លោកយ៉ូសែបបានសុំឲ្យបងៗរបស់គាត់ នាំប្អូនប្រុសរបស់គេបេនយ៉ាមីនមកវិញ ។
4) លោកយ៉ូសែបបានលាក់ពែងប្រាក់នៅក្នុងសាកាដូរបស់បេនយ៉ាមីន ។
5) យូដា ដែលជាបងប្រុសម្នាក់បាននិយាយថា គាត់នឹងធ្វើជាទាសករជំនួសបេនយ៉ាមីនសម្រាប់យ៉ូសែបវិញ ។
6) ក្រោយពីលោកយ៉ូសែបបានប្រាប់ដល់បងប្អូនគាត់ថា គាត់ជានរណាហើយ គាត់បានប្រាប់ពួកគេឲ្យទៅផ្ទះនាំយកឪពុក សមាជិកគ្រួសារទាំងប៉ុន្មាន និងសត្វរបស់ពួកគេទាំងអស់ នាំត្រឡប់ទៅស្រុកអេស៊ីព្ទវិញ។ គាត់នឹងរកកន្លែងសម្រាប់ពួកគេរស់នៅ ។


Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org